និយាយមែនទេន!!!!!!!!!!!!!!!!!!!!!!!!!!!!!

ក្រោយពីព្រិត្តការណ៍ នៃការបោះឆ្នោតបានកន្លងផុតទៅ  សភាពការណ៍នយោបាយក្នុងប្រ ទេសកន្តុជាយើង បានវិលត្រឡប់ទៅរកភាពប្រក្រតី  ទោះបីជាមានការជំទាស់មកពីគណបក្ស ប្រឆាំងក្តី ក៏បញ្ហានេះមិនមែន ជាឧបសគ្គ ដែលអាចរាំងស្ទះដល់ដំណើរការ នៃការបង្កើតរដ្ឋាភិបាលបានឡើយ  ។ជ័យជំនះរបស់គណ បក្សប្រជាជន បានធ្វើអោយ អ្នកគាំទ្រគណបក្សនេះ មានការសប្បាយអរវីករាយ យ៉ាងក្រៃ លែង។ តែទន្ទឹមនឹងគ្នានេះដែរ  ក៏មានអ្នកគាំទ្រមួយចំនួនបានរអ៊ូរទាំ អំពីការខាតបង់ថវិការផ្ទាល់ខ្លួន ស្ទើតែជា រាងរាល់ខែ ដែលជាការចំណាយ សម្រាប់ធ្វើអំណោយ ដើម្បីទិញទឹកចិត្តប្រជាពលរដ្ឋ អោយពលរដ្ឋ ទាំងនោះ លោកបោះ ឆ្នោតជូនគណបក្សប្រជាជននេះ ។ អ្វីដែលមិនធម្មតានោះ គឺការចំណាយទាំងឡាយ នោះ គឺកាន់តែមានចំនួនកើនឡើងពីមួយអាណត្តិទៅមួយអាណត្តិ  ទាំងនេះគឺដោយសាតែទីផ្សារនៃការ អែបអប ដើម្បីទទួលបាននូវមុខងា ជាពិសេសមុខដំណែងណា  ដែលអាចនាំមកនូវអំណាចព្រម ទាំងលាភសក្ការះ  កាន់តែមានតម្លៃខ្ពស់ជាលំដាប់  ។ឥឡូវនេះ  អ្វីដែលគួអោយបារម្ភណ៍នោះ គឺការស្រង់ដើម  ពីព្រោះថា ចាប់ពីពេលនេះតទៅ គឺជា ពេលវេលាដែល អស់លោក ឯកឧកញ៉ា ឯកឧត្តម លោកជំទាវ លោកប្រុស លោកស្រី ព្រមទាំងមន្ត្រីតូចធំ ទាំងឡាយណា  ដែលបានបណ្តាក់ទុន ជាមួយលោកហ៊ុនសែន  គឺពួកលោក នឹងត្រូវប្រមូលយក ទាំងកា ទាំងដើមមក វិញ អោយខានតែបាន  !! មួយវិញទៀត  ទៅថ្ងៃអនាគត  គេនឹងឃើញមាន ឃ្លាអក្សដែលសរសេរថា (អំណោយរបស់លោកនាយក រដ្ឋមន្ត្រីហ៊ុនសែននឹងលោកជុំទាវប៊ុនរ៉ានី )មានពាសពេញនគរ  ដូចជានៅតាមគ្រប់ សាលារៀន  ព្រះវិហារ កុដិ ក្លោងទ្វារ ស្ពាន  មន្ទីពេទ្យ ពន្ធធនាគារ បន្ទាយទាហាន  ផ្លូវទូរគមនាគមន៍ បឹងបួ ទន្លេ  អង្គរវត្ត ប្រាសាទព្រះវិហារ  ។ល។  មិនតែប៉ុណ្ណោះ សូម្បីតែ កូនក្មេងជំនាន់ក្រោយ កើតមកភ្លាម ក៏មានឆ្លាក់ ឃ្លាអក្សនេះ មកជាមួយផង ដែរ៕          ជយោ! មហាពុករលួយ  ជយោ! មហាអែបអប

ជយោ!មហា អោនលំទោម  ជយោ!មហាកំសាក  ។                              បងធំ